**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សូមក្រាបបង្គំទូលថ្វាយ

## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥

***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ "សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប" ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ទូលព្រះបង្គំនិងភរិយា ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្តក្រាបបង្គំទូលថ្វាយនូវព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ។

ទូលព្រះបង្គំជាកូន ចៅ ចៅទួតទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះមហាករុណាធិគុណដ៏ធំធេងរបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និងចងចាំជានិច្ចចំពោះព្រះរាជស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមចំពោះជាតិ និងប្រជារាស្ត្រតាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ សេចក្តីថ្លៃថ្នូររបស់ស្ត្រី លើកស្ទួយវិស័យអប់រំសិក្សាធិការ សុខុមាលភាព វិស័យសង្គមកិច្ច ព្រះពុទ្ធសាសនា និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជារាស្ត្រ ប្រកបដោយព្រះរាជទសពិធរាជធម៌ ដើម្បីបុព្វហេតុជាតិ សាសនា មាតុភូមិជាទីស្នេហា។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តលើកហត្ថប្រណម្យបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា និងបារមីនៃអតីតព្រះមហាក្សត្រ មហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោះព្រំសព្ទសាធុការពរជ័យសិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ សូមព្រះអង្គប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់នៅជាម្លប់ដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នាជាកូន ចៅ ចៅទួតរបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃសុក្រ ២ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ខែកុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៧៤ email: generalsec@mod.gov.kh